**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស. ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ វិធាន និងនីតិវិធីនៃការប្រមូល ការបង់ ការកៀរគរ ការកត់ត្រា ការតាមដាន និងការត្រួតពិនិត្យវាយតម្លៃលើចំណូលមិនមែនសារពើពន្ធ ព្រមទាំងការចាត់វិធានអនុវត្តកិច្ចសន្យា និងការតឹងទារបំណុលមិនមែនសារពើពន្ធ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

**មាត្រា៤.-**

បច្ចេកស័ព្ទ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចតទៅ÷

- **ចំណូលមិនមែនសារពើពន្ធ** សំដៅដល់ចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេស និងចំណូលផ្សេងទៀតដែលត្រូវបានកំណត់ថាជាចំណូលមិនមែនសារពើពន្ធដទៃទៀត។
- **បំណុលមិនមែនសារពើពន្ធ** សំដៅដល់ចំនួនទឹកប្រាក់នៃចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលមិនទាន់ប្រមូលបាន ពីព្រោះអ្នកជាប់កាតព្វកិច្ចបង់ចំណូល ខកខានមិនបានបំពេញកាតព្វកិច្ចបង់ចំណូល ក្នុងរយៈពេលនិងលក្ខខណ្ឌដែលបានកំណត់។
- **សេវាសាធារណៈ** សំដៅដល់សេវាដែលផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាព នៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅឱ្យវិស័យឯកជន ឬសាធារណជន ដោយយកកម្រៃ ឬមិនយកកម្រៃ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- **អង្គភាពស្វ័យភាពហិរញ្ញវត្ថុ** សំដៅដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រឹះស្ថានសាធារណៈសុខាភិបាល និងអង្គភាពដទៃទៀត ដែលមានស្វ័យភាពហិរញ្ញវត្ថុ។

- **អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ** សំដៅដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ទីចាត់ការហិរញ្ញវត្ថុ ការិយាល័យ ឬផ្នែកដែលទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ នៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ។
- **រូបមន្តសមាស ឬរូបមន្តគរពួន** សំដៅដល់ការគណនាប្រាក់ពិន័យ ដោយត្រូវយកបំណុលដើមគុណនឹងអត្រាពិន័យយ៉ាងតិច ២% (ពីរភាគរយ) ក្នុងមួយខែ បូកយោងជាបន្តបន្ទាប់តាមចំនួនខែដែលជំពាក់ ដែលមានរូបមន្ត÷ $X(1+r)^n$ ដោយ X ជាបំណុលដើម, r ជាអត្រាពិន័យក្នុងមួយខែ, n ជាចំនួនខែ។
- **ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់។
- **ភាគចំណែករបស់រដ្ឋ** គឺជាចំណូលរបស់រដ្ឋដែលបានមកពីការបែងចែកអត្រានៃផលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, ប្រតិបត្តិការអាជីវកម្មរវាងរដ្ឋនិងឯកជន, ផលបានពីសម្បទានពីទ្រព្យសម្បត្តិរដ្ឋ និងផលដទៃទៀតតាមការកំណត់ក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ។
- **ចំណូលដុល** គឺសំដៅដល់ចំណូលទាំងឡាយដែលមិនទាន់កាត់កងចំណាយណាមួយ នៅក្នុងសកម្មភាពអាជីវកម្ម។
- **ចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុ** គឺជាចំណូលដែលបានមកពីវិស័យឧស្សាហកម្មហិរញ្ញវត្ថុ ដូចជា វិស័យធានារ៉ាប់រងនិងសោធន, អាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ, អាជីវកម្មអចលនវត្ថុ, បញ្ចាំ, ប្រាតិភោគដោយអនុប្បទាន និងវិស័យទីផ្សារហិរញ្ញវត្ថុ។

## ជំពូកទី២
## យន្តការស្ថាប័ន
### ផ្នែកទី១
### យន្តការស្ថាប័នថ្នាក់ជាតិ

**មាត្រា៥._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យលើការប្រមូលចំណូលមិនមែនសារពើពន្ធ និងមានភារកិច្ច ដូចតទៅ÷

- រៀបចំក្របខ័ណ្ឌគតិយុត្ត ពាក់ព័ន្ធការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចំណូលមិនមែនសារពើពន្ធ
- ជំរុញការកៀរគរ និងការកត់ត្រា នូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំការតឹងទារបំណុលមិនមែនសារពើពន្ធ
- គ្រប់គ្រង តាមដាន និងត្រួតពិនិត្យរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ត្រួតពិនិត្យ និងវាយតម្លៃភាពត្រឹមត្រូវ នៃរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ អនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ និងលើកសំណើដំណោះស្រាយលើ

បញ្ហាប្រឈមនានា ពាក់ព័ន្ធគណនេយ្យភាព និងបូរណភាពនៃការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច

- រៀបចំសំណើវិធានការលើកទឹកចិត្ត ឬសំណើវិធានការរឹតត្បិត ពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ចហិរញ្ញវត្ថុ លើការអនុវត្តចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំដោះស្រាយបញ្ហាពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ដោយរាយការណ៍ជូននាយករដ្ឋមន្ត្រី។

**មាត្រា៦.–**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំពេញភារកិច្ចក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដូចតទៅ÷

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ សម្រាប់ច្បាប់ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ
- ដឹកនាំ និងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- កៀរគរ កត់ត្រាចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលប្រមូលបាន
- ចាត់វិធានការលើបំណុលមិនមែនសារពើពន្ធ ដែលត្រូវតឹងទារ
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ដោះស្រាយបញ្ហាពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីដែលពុំអាចដោះស្រាយបាន។

**មាត្រា៧.–**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង្កើតក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៃសាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា “**ក.គ.ម.**” ដើម្បីបំពេញមុខងារជាសេនាធិការ ក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធរបស់សាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

**ក.គ.ម.** នៃ ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មានសមាសភាព ដូចខាងក្រោម÷

- រដ្ឋលេខាធិការ ឬតំណាង ទទួលបន្ទុកការងារគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ នៃក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មួយរូប ............ ប្រធាន
- អនុរដ្ឋលេខាធិការ ឬតំណាង ទទួលបន្ទុកការងារគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ នៃក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មួយចំនួន ............ អនុប្រធាន
- ប្រធានអង្គភាពអនុវត្តការប្រមូលចំណូលនៅថ្នាក់កណ្ដាលនិងនៅថ្នាក់មូលដ្ឋាន ............ សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ............ សមាជិកអចិន្ត្រៃយ៍ និង ជាប្រធានលេខាធិការដ្ឋាន។

សមាសភាពជាក់ស្ដែងនៃ **ក.គ.ម.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់សាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃ **គ.គ.ម.** ត្រូវកំណត់ដោយប្រកាស ឬសេចក្តីសម្រេចរបស់សាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៨._**

**គ.គ.ម.** នៃក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មានភារកិច្ច ដូចខាងក្រោម÷

- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលអនុវត្តដោយអង្គភាពក្រោមឱវាទ
- កៀរគរ និងកត់ត្រា នូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់សាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ចូលរួមពង្រឹងទារបំណុលមិនមែនសារពើពន្ធ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ប្រចាំសាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីដាក់ជូនប្រធានស្ថាប័នពិនិត្យ និងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លើកសំណើដោះស្រាយបញ្ហាពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីនៃក្រសួង និងប្រធានស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៩._**

**គ.គ.ម.**នៃ ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មានលេខាធិការដ្ឋានមួយ ជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ នៃក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាលេខាធិការដ្ឋាន នៃ **គ.គ.ម.** ដោយមានភារកិច្ច ដូចតទៅ÷

- ធានាកិច្ចដំណើរការប្រចាំថ្ងៃ និងរៀបចំកិច្ចប្រជុំរបស់ក្រុមការងារ
- ត្រួតពិនិត្យតាមដានការអនុវត្តចំណូលមិនមែនសារពើពន្ធ របស់អង្គភាពក្រោមឱវាទសាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- កៀរគរ និងកត់ត្រា នូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ចូលរួមពង្រឹងទារបំណុលមិនមែនសារពើពន្ធ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីដាក់ជូន **គ.គ.ម.**
- សម្របសម្រួលដោះស្រាយបញ្ហាពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាន **គ.គ.ម.**។

## ផ្នែកទី២
## យន្តការស្ថាប័នថ្នាក់ក្រោមជាតិ

**មាត្រា១០.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត បំពេញមុខងារជាសេនាធិការ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា១១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ច ដូចតទៅ÷

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ សម្រាប់ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ
- ដឹកនាំនិងគ្រប់គ្រងការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ជំរុញការកៀរគរ និងការកត់ត្រា នូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញ នៃរាជធានី ខេត្ត
- ចូលរួមដឹកនាំតឹងទារបំណុលមិនមែនសារពើពន្ធ នៅរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញ នៃរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញ នៃរាជធានី ខេត្ត ដើម្បីបញ្ជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដោះស្រាយបញ្ហាពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីដែលពុំអាចដោះស្រាយបាន។

**មាត្រា១២.-**

ក្នុងករណីចាំបាច់ រដ្ឋបាលរាជធានី ខេត្ត អាចបង្កើតជាគណៈកម្មការ ឬក្រុមការងារ ជាសេនាធិការ ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ។

## ផ្នែកទី៣
## នីតិវិធីរៀបចំរបាយការណ៍អនុវត្តចំណូលមិនមែនសារពើពន្ធនៅថ្នាក់ជាតិ

**មាត្រា១៣.-**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ បូកសរុបរបាយការណ៍ស្តីពីការអនុវត្តចំណូលមិនមែនសារពើពន្ធ ទាំងអង្គភាពថ្នាក់កណ្តាល ទាំងមន្ទីរជំនាញ នៃរាជធានី ខេត្ត ក្រោមឱវាទសាមីក្រសួង ស្ថាប័ន ដែលប្រមូល

ចំណូលមិនមែនសារពើពន្ធ ជូនប្រធានស្ថាប័នសាមី ពិនិត្យនិងសម្រេច និងបញ្ជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤

## នីតិវិធីរៀបចំរបាយការណ៍អនុវត្តចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិ

**មាត្រា១៤.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ បូកសរុបរបាយការណ៍ស្ដីពីការអនុវត្តចំណូលមិនមែនសារពើពន្ធ របស់មន្ទីរជំនាញ នៃរាជធានី ខេត្ត ក្រោមឱវាទក្រសួង ស្ថាប័ន និងរបស់រាជធានី ខេត្ត ដែលប្រមូលចំណូលមិនមែនសារពើពន្ធ បញ្ជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៣

# ចំណូលមិនមែនសារពើពន្ធ

## ផ្នែកទី១

## ប្រភេទនៃចំណូលមិនមែនសារពើពន្ធ

**មាត្រា១៥.-**

ចំណូលមិនមែនសារពើពន្ធ ត្រូវបានបែងចែកជា ៥ ប្រភេទ ដូចខាងក្រោម÷

១. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ

២. ចំណូលពីសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត

៣. ចំណូលពីសេវាសាធារណៈ

៤. ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម

៥. ចំណូលមិនមែនសារពើពន្ធផ្សេងទៀត។

## ផ្នែកទី២

## ចំណូលពីទ្រព្យសម្បត្តិរដ្ឋ

**មាត្រា១៦.-**

ចំណូលពីទ្រព្យសម្បត្តិរដ្ឋ សំដៅដល់ចំណូលដែលទទួលបានពីការចាត់ចែង ការធ្វើអាជីវកម្ម និងផលបានពីសម្បទាន លើទ្រព្យសម្បត្តិរដ្ឋ ដែលរួមមានជាអាទិ៍÷

១-ចំណូលពីការលក់ទ្រព្យសម្បត្តិរដ្ឋ

២-ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ

៣-ចំណូលពីការផ្ដល់សិទ្ធិសម្បទាននានា ដែលមានជាអាទិ៍ ផ្សារ កំពង់ផែ ចំណតរថយន្ត ចំណតទូកកាណូត កំពង់ផែនេសាទ យឿត្រី ទីសត្តឃាត អនាម័យសត្វ ទីតាំងដាក់សំរាម

៤-ចំណូលពីកម្រៃសួយសារនៃធនធានធម្មជាតិ

៥-ភាគចំណែករបស់រដ្ឋតាមរយៈការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិជាមួយបុគ្គលឯកជន

៦-ចំណូលពីការផ្ដល់សម្បទានធនធានធម្មជាតិនិងហេដ្ឋារចនាសម្ព័ន្ធ

៧-ចំណូលផ្សេងៗទៀត ដែលមានចែងក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត។

**មាត្រា១៧.-**

រាល់ការចុះកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវទទួលការពិនិត្យនិងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេច ក្នុងរយៈពេលមិនលើសពី ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀតខាងលើ។

រាល់ការកែប្រែកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវទទួលការពិនិត្យ និងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពពេញលេញនៃការអនុវត្តកិច្ចសន្យា ឬកិច្ចព្រមព្រៀង ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ កិច្ចសន្យា ឬកិច្ចព្រមព្រៀងនេះត្រូវបញ្ចូលលក្ខខណ្ឌនៃការបង់ប្រាក់កក់ ដែលមានចំនួនកំណត់ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការចុះហត្ថលេខា លើកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តនានា ទៅឱ្យតំណាង ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយអនុលោមតាមវិធាននិងនីតិវិធីជាធរមាន។

**មាត្រា១៨.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការកែប្រែកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត ដែលពិនិត្យឃើញថាមានភាពមិនប្រក្រតីណាមួយ ដែលធ្វើឱ្យបាត់បង់ចំណូល ឬនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

## ផ្នែកទី៣

## ចំណូលពីសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត

**មាត្រា១៩.-**

ចំណូលពីសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត សំដៅដល់ចំណូលពីការបង់ភាគលាភ និងអតិរេកថវិការបស់សហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

**មាត្រា២០.-**

ភាគលាភ គឺជាចំណែកទឹកប្រាក់ដែលបានពីការបែងចែកប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមការសម្រេចរបស់រាជរដ្ឋាភិបាល។ អតិរេកថវិកា គឺជាចំនួនទឹកប្រាក់ដែលត្រូវបង់ចូលថវិការដ្ឋ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានការទទួលស្គាល់ពីអាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីពុំមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន សហគ្រាសសាធារណៈ ឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវមានកាតព្វកិច្ចបង់ភាគលាភ ឬអតិរេកថវិកា ចូលថវិការដ្ឋយ៉ាងតិចចំនួន ១០% (ដប់ភាគរយ) នៃប្រាក់ចំណេញសុទ្ធ ឬអតិរេកថវិកា ដោយអនុលោមទៅតាមបែបបទនិងនីតិវិធី នៃការបង់ភាគលាភ ឬអតិរេកថវិកា ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការគ្រប់គ្រងចំណូលរបស់សហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត នឹងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី៤
## ចំណូលពីសេវាសាធារណៈ

**មាត្រា២១.-**

ចំណូលពីសេវាសាធារណៈ សំដៅដល់ចំណូល ដែលប្រមូលបានពីការបង់កម្រៃ នៃការប្រើប្រាស់សេវាសាធារណៈ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋ ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច ក្នុងគោលដៅបម្រើសេវាសាធារណៈ។

**មាត្រា២២.-**

ចំណូលពីសេវាសាធារណៈ ត្រូវបានបែងចែកជា ៥ ប្រភេទ ដូចខាងក្រោម÷

១-ចំណូលពីសេវាសាធារណៈក្នុងវិស័យរដ្ឋបាលទូទៅ

២-ចំណូលពីសេវាសាធារណៈក្នុងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៣-ចំណូលពីសេវាសាធារណៈក្នុងវិស័យសង្គមកិច្ច

៤-ចំណូលពីសេវាសាធារណៈក្នុងវិស័យសេដ្ឋកិច្ច

៥-ចំណូលពីសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា២៣.-**

កម្រៃសេវាសាធារណៈរបស់រដ្ឋ ត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

កម្រៃសេវាសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈតូចតាចមានជាអាទិ៍ កម្រៃពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ប័ណ្ណចូលទស្សនារមណីយដ្ឋាន សារមន្ទីរ វិក្កយបត្រពិន័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធ។

កម្រៃសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្រៃសេវាសាធារណៈ ដែលធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ននានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

**មាត្រា២៤.-**

សេវាសាធារណៈ ដែលផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា, តម្លៃសេវា, រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

## ផ្នែកទី៥
## ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម

**មាត្រា២៥.-**

ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម សំដៅដល់ចំណូល ដែលបានពីការពិន័យជាប្រាក់ ដែលធ្វើឡើងដោយស្ថាប័នរដ្ឋបាល ឬស្ថាប័នតុលាការ ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាននិងផលពី

ការរឹបអូសទុកជាសម្បត្តិរដ្ឋ ដោយសេចក្តីសម្រេចស្ថាពររបស់តុលាការ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ ឬថវិកាថ្នាក់ក្រោមជាតិ។

**មាត្រា២៦.-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងប្រមូលចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី។

## ផ្នែកទី៦

## ចំណូលមិនមែនសារពើពន្ធផ្សេងទៀត

**មាត្រា២៧.-**

ចំណូលមិនមែនសារពើពន្ធផ្សេងទៀត រួមមានជាអាទិ៍÷ ចំណូលពីទ្រព្យនិទាយាទភាព, ប្រទានកម្ម, អច្ច័យទាន, ចំណូលពីផលហិរញ្ញវត្ថុ, ចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុ, ផលផ្សេងៗ, និងផលពិសេសផ្សេងទៀត។

**មាត្រា២៨.-**

ចំណូលពីទ្រព្យនិទាយាទភាព សំដៅដល់ចំណូលបានមកពីទ្រព្យ ដែលពុំមានសន្តតិជន ហើយត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ចំណូលពីប្រទានកម្ម និងអច្ច័យទាន សំដៅដល់ចំណូលទទួលបានក្រោមទម្រង់ជាអំណោយ ដែលអាចជាហិរញ្ញវត្ថុ ឬសម្ភារៈ រួមមាន ការឧបត្ថម្ភកធនទ្វេភាគី ពហុភាគី និងជំនួយឥតសំណងផ្សេងៗទៀត។

ផលហិរញ្ញវត្ថុ សំដៅដល់ផលហិរញ្ញវត្ថុទាំងអស់ ដែលបានមកដោយការយកអតិរេកសាច់ប្រាក់បណ្តោះអាសន្នទៅវិនិយោគលើមូលបត្រអាចជួញដូរបាន និងក្នុងរយៈពេលខ្លី។ ផលហិរញ្ញវត្ថុនេះ មានជាអាទិ៍ អត្រាការប្រាក់លើបំណុលប្រាក់ចំណេញ ដែលបានមកពីការវិនិយោគក្នុងរយៈពេលមួយយប់ លើប័ណ្ណរតនាគារបរទេស ផលដែលបានមកពីការធានាឱ្យមានសំវិធានធន និងកម្រៃជទៃទៀតដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ។

ផលផ្សេងៗ និងផលពិសេស សំដៅដល់ចំណូលពីការបង់អតិរេករបស់ថវិកាថ្នាក់ក្រោមជាតិ, ចំណូលពីអតិរេករបស់ថវិការដ្ឋ, ចំណូលពីសមតុល្យចុងឆ្នាំនៃមូលនិធិក្រុង ស្រុក, កម្រៃរតនាគារ, ចំណូលពីការលក់ផ្តាច់ ឬប្រាក់លម្អៀងពីការដោះដូរទ្រព្យសម្បត្តិអចលកម្មរបស់រដ្ឋ, ទឹកប្រាក់បង្វិលចូលថវិការដ្ឋ ដោយការបើកផ្តល់លើសសម្រាប់ការអនុវត្តគម្រោង និងផល ឬចំណូលផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៩.-**

វិធាននិងនីតិវិធី នៃការគ្រប់គ្រងនិងប្រមូលចំណូលពីទ្រព្យនិទាយាទភាព, ប្រទានកម្ម, អច្ច័យទាន, ចំណូលពីផលហិរញ្ញវត្ថុ, ផលផ្សេងៗ និងផលពិសេសផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៧

## គោលការណ៍ក្នុងការបង់ចំណូលមិនមែនសារពើពន្ធ

**មាត្រា៣០.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់ ឬមូលប្បទានបត្រនៅក្នុងបេឡាជូទេយ្យករចំណូល លើសពីកម្រិតទឹកប្រាក់អតិបរមាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើយ។

**មាត្រា៣១.-**

ចំណូលមិនមែនសារពើពន្ធ ត្រូវបង់តាមគោលការណ៍ ដូចខាងក្រោម÷

- បង់ចូលគណនីទោលរបស់រតនាគារ ឬធនាគារដៃគូ
- បង់តាមរយៈរជ្ជទេយ្យករចំណូល ឬភ្នាក់ងារប្រមូលចំណូល។

វិធាននិងនីតិវិធី នៃការបង់ចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣២.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដែលធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈរជ្ជទេយ្យករចំណូល ត្រូវបង់ចំណូលប្រមូលបានទាំងអស់ចូលគណនីប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យករចំណូលនិងធ្វើសលាកបត្រចំណូលថវិកាថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ដោយមិនត្រូវប្រើប្រាស់ចំណែកណាមួយនៃប្រាក់ចំណូល យកទៅកាត់កងដោយត្រង់ជាមួយចំណាយ ឬរក្សាទុកចំណូលខ្លះ សម្រាប់ការចំណាយពិសេសណាមួយ លើកលែងតែមានគោលការណ៍អនុញ្ញាតដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមានគោលការណ៍បើកផ្តល់ប្រាក់បុរេប្រទានដោយដកយកពីចំណូលថវិកាជាតិ ដែលកំណត់ដោយប្រកាសរួមសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្តឱ្យបានទាន់ពេលវេលាជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី៤
## ការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធ

**មាត្រា៣៣.-**

នៅក្នុងរចនាសម្ព័ន្ធថវិកា ចំណូលមិនមែនសារពើពន្ធ គឺជាផ្នែកមួយនៃចំណូលចរន្តនៃធនធានអចិន្ត្រៃយ៍របស់រដ្ឋ។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូល ចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំឱ្យបានពេញលេញនិងត្រឹមត្រូវ ដែលផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាអាទិភាពនៃផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដោយរៀបចំបញ្ជីរាយមុខចំណូលនិងការប៉ាន់ស្មានចំណូលទៅតាមមុខចំណូលនីមួយៗ ព្រមទាំងធ្វើចំណាត់ថ្នាក់មុខចំណូលទាំងនោះទៅតាមជំពូក គណនី អនុគណនីនៃមាតិកាចំណូលថវិកា។

ការគ្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ត្រូវមានមូលដ្ឋានគ្រោងគិតចំណូលទៅតាមមុខចំណូលនីមួយៗឱ្យបានច្បាស់លាស់ ដោយផ្អែកលើបញ្ជីស្ថិតិបច្ចុប្បន្នភាព, បញ្ជីសម្រង់ទិន្នន័យ និងស្ថានភាព នៃការអនុវត្តចំណូល និងបំណុលនាឆ្នាំកន្លងមក, ការរំពឹងលើប្រភពចំណូលថ្មី, តម្លៃសេវាសាធារណៈ, ទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើស, តម្លៃដូចមានកំណត់ក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត, ការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។

**មាត្រា៣៤.-**

ការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំឡើងឱ្យស្របទៅតាមទម្រង់បែបបទ នីតិវិធីបច្ចេកទេស និងគោលការណ៍ជាមូលដ្ឋាននានា ដែលកំណត់ដោយសារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការ

គ្រប់គ្រងប្រចាំឆ្នាំ ចំពោះរដ្ឋបាលថ្នាក់ជាតិ និងសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមវិធាននិងនីតិវិធី នៃការរៀបចំថវិកា ដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ដើម្បីត្រៀមការអនុវត្តគម្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ និងបរិមាណទិដ្ឋាការស្អិត ដែលត្រូវប្រើប្រាស់សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំដែលបានគ្រោង និងផ្ញើគម្រោងនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំរៀបចំគម្រោងតម្រូវការ ដោយភ្ជាប់មកជាមួយនឹងគម្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមូលដ្ឋានសម្រាប់ការពិនិត្យ ពិភាក្សា និងសម្របសម្រួលឱ្យបានសមស្រប។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ ដែលត្រូវប្រើប្រាស់សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំដែលបានគ្រោង និងផ្ញើគម្រោងនេះមក មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីពិនិត្យនិងបូកសរុបបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំរៀបចំគម្រោងតម្រូវការ ដោយភ្ជាប់មកជាមួយនឹងគម្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមូលដ្ឋានសម្រាប់ការពិនិត្យ ពិភាក្សា និងសម្របសម្រួល ឱ្យបានសមស្រប។

**មាត្រា៣៥.-**

ក្នុងក្របខ័ណ្ឌឥណទានចំណូល ដែលត្រូវបានកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំកម្មវិធីចំណូលមិនមែនសារពើពន្ធសម្រាប់រយៈពេលមួយឆ្នាំ ដោយបែងចែកកម្មវិធីចំណូលទៅតាមត្រីមាស និងលម្អិតតាមខែនីមួយៗ ព្រមទាំងរាយលម្អិតគ្រប់មុខចំណូល ទៅតាមជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវផ្ញើកម្មវិធីចំណូលប្រចាំឆ្នាំ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំអនុវត្តកម្មវិធីចំណូល។

## ជំពូកទី៥

## ការអនុវត្តចំណូល ការគ្រប់គ្រង និងការតាមដានចំណូលមិនមែនសារពើពន្ធ

### ផ្នែកទី១

### ការប្រមូលចំណូលមិនមែនសារពើពន្ធ

**មាត្រា៣៦.-**

ចំពោះការប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវអនុវត្តការប្រមូលចំណូល ការតាមដាន ការត្រួតពិនិត្យវាយតម្លៃលើការប្រមូលចំណូល ស្របតាមវិធាននិងនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៣៧.-**

នៅរៀងរាល់ដំណាច់ខែនីមួយៗ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការបូកសរុបចំណូលដែលទទួលបានតាមរយៈគណនីទោលរបស់រតនាគារ ឬគណនីរបស់ធនាគារដៃគូ និងរជ្ជទេយ្យ

ចំណូល ដើម្បីធ្វើបញ្ជីស្ថិតិគ្រប់មុខសញ្ញាចំណូលទាំងអស់ ដែលជាកម្មវត្ថុនៃការប្រមូលចំណូល និងតាមដានទឹកប្រាក់ចំណូលត្រូវប្រមូល, ចំណូលប្រមូលបាន និងចំណូលត្រូវប្រមូលបន្ត ដោយមានកំណត់សម្គាល់អំពីស្ថានភាពប្រមូលចំណូលទៅតាមមុខសញ្ញាចំណូលទាំងនោះ។

**មាត្រា៣៨.-**

ចំពោះការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលគ្រប់គ្រង បោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការប្រើប្រាស់ប្រភេទបង្កាន់ដៃបង់ប្រាក់អេឡិចត្រូនិច ឬប្រភេទបង្កាន់ដៃបង់ប្រាក់ទម្រង់ផ្សេងទៀត សម្រាប់ការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## ការបង់ចំណូលចូលថវិកាជាតិ

**មាត្រា៣៩.-**

នៅរៀងរាល់ចុងខែនីមួយៗ យោងតាមចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានតាមរយៈគណនីទោលរបស់រតនាគារ ឬគណនីរបស់ធនាគារដៃគូ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើសលាកប័ត្រចំណូលថវិកាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដែលជាសក្ខីប័ត្រមូលដ្ឋាន សម្រាប់គណនេយ្យករសាធារណៈនៅរតនាគារ ដើម្បីបំពេញនីតិវិធីកត់ត្រាជាចំណូលថវិកាជាតិ ។

**មាត្រា៤០.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ប្រាក់ចំណូល ដែលប្រមូលបានតាមរយៈរជ្ជទេយ្យចំណូល ដូចខាងក្រោម÷

- ត្រូវពិនិត្យ និងបង់ប្រាក់ចំណូលចូលគណនីទោលរបស់រតនាគារ ឬគណនីរបស់ធនាគារដៃគូ ដើម្បីកុំឱ្យទឹកប្រាក់ក្នុងបេឡារបស់រជ្ជទេយ្យករចំណូល កើនលើសកម្រិតទឹកប្រាក់អតិបរមាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវបង់ប្រាក់ចំណូលទាំងអស់ចូលថវិកាជាតិនៅរៀងរាល់ចុងខែ ក្នុងករណីចំណូលប្រមូលបាននៅក្នុងខែណាមួយ មានចំនួនទឹកប្រាក់ទាបជាងកម្រិតទឹកប្រាក់អតិបរមា នៃរជ្ជទេយ្យចំណូល។

ការបង់ប្រាក់ចំណូល ត្រូវធ្វើឡើងតាមរយៈសលាកប័ត្របង់ចំណូលថវិកាជាតិ យ៉ាងហោចណាស់ម្តងក្នុងមួយខែដើម្បីបំពេញនីតិវិធីកត់ត្រាជាចំណូលថវិកាជាតិ។

**មាត្រា៤១.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដែលទទួលបានគោលការណ៍ផ្តល់រង្វាន់លើកទឹកចិត្ត និងបានបុរេប្រទានថវិកាពីប្រាក់ចំណូលប្រមូលបានលើការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវអនុវត្តនីតិវិធីទូទាត់ក្នុងរយៈពេល ១ (មួយ) ខែ ដោយអនុលោមតាមគោលការណ៍និងនីតិវិធី ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣
## បំណុលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ

**មាត្រា៤២.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវត្រួតពិនិត្យតាមដានជាប្រចាំ លើកាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមានកំណត់ក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត។

ក្នុងករណីពិនិត្យឃើញថា ការបង់ចំណូលហួសឥណប្រតិទាន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវមានវិធានការលើបំណុលមិនមែនសារពើពន្ធ ដូចខាងក្រោម÷

- ក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់÷ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតរំលឹកដល់អ្នកជាប់កាតព្វកិច្ចឱ្យបង់ចំណូល។
- លើសពីរយៈពេល ៦០(ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់÷ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់វិធានការលើបំណុលដែលត្រូវតឹងទារ និងត្រូវពិន័យយ៉ាងតិច ២% (ពីរភាគរយ) ក្នុងមួយខែ លើចំនួនទឹកប្រាក់បំណុលដើម និងទឹកប្រាក់ពិន័យកន្លងមកដែលនៅមិនទាន់បានបំពេញកាតព្វកិច្ចបង់សងជូនភាគីរដ្ឋ ដោយគិតចាប់ពីថ្ងៃដំបូងដែលបានកត់ត្រាជាបំណុលមិនមែនសារពើពន្ធ។ ទោះបីជាការបង់សងបំណុល ធ្វើឡើងក្នុងថ្ងៃណាមួយនៃខែបច្ចុប្បន្នក៏ដោយ ក៏ត្រូវទទួលរងការពិន័យយ៉ាងតិច ២% (ពីរភាគរយ) ដោយត្រូវគិតពេញមួយខែដែរ។ ចំនួនទឹកប្រាក់ពិន័យនៃខែនីមួយៗ ត្រូវបានគណនាតាមរូបមន្តសមាស ឬ រូបមន្តគរពូនសម្រាប់ខែបន្តបន្ទាប់ ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។
- ផុតរយៈពេល ៦(ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់÷ ក្នុងករណីអ្នកជាប់កាតព្វកិច្ចនៅតែមិនទូទាត់បំណុលរបស់ខ្លួន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបញ្ជូនសំណុំរឿងនិងឯកសារភ័ស្តុតាងទាំងអស់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្តល់កិច្ចសហការ ដើម្បីចាត់វិធានការតឹងទារបំណុល តាមរយៈយន្តការក្រុមការងារអន្តរក្រសួង ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៤៣.-**

រយៈពេល និងអត្រានៃការពិន័យ ដូចមានចែងក្នុងមាត្រា៤២ ខាងលើ គឺជាវិធានអប្បបរមា ដែលមានឧត្តមានុភាពលើកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក លិខិតគតិយុត្តផ្សេងទៀត ឬលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលកំណត់រយៈពេលវែងជាង និងអត្រានៃការពិន័យតិចជាង ប៉ុន្តែវិធានអប្បបរមានេះ ត្រូវបាត់បង់អានុភាព ក្នុងករណីដែលកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក លិខិតគតិយុត្តផ្សេងទៀត ឬលិខិតបទដ្ឋានគតិយុត្តដោយឡែក បានកំណត់រយៈពេលខ្លីជាង និងអត្រានៃការពិន័យច្រើនជាង។

វិធាននិងនីតិវិធីលម្អិតនៃការតឹងទារបំណុលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៤.-**

ចំពោះប្រភេទចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលមានលក្ខណៈងាយនឹងកើតមានបំណុលមិនមែនសារពើពន្ធ សាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបញ្ជីតាមដានការប្រមូលចំណូលមិនមែនសារពើពន្ធទាំងនោះ ដោយមានរាយប្រភេទនៃមុខចំណូល ឈ្មោះអ្នកជាប់កាតព្វកិច្ច និងធ្វើការវិភាគអំពីចំនួនទឹកប្រាក់ចំណូលត្រូវតឹងទារនៅក្នុងរយៈពេលធម្មតាដែលបានកំណត់ឱ្យបង់ប្រាក់ ចំនួនទឹកប្រាក់បំណុល ចំនួនទឹកប្រាក់ពិន័យដែលត្រូវអនុវត្តលើបំណុល ព្រមទាំងធ្វើកំណត់សម្គាល់ និងបច្ចុប្បន្នភាពអំពីស្ថានភាពបំណុលទាំងនោះ។ វិធាននិងនីតិវិធីលម្អិត នៃការតាមដានបំណុលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤

## ការកត់ត្រាតាមដាន និងការធ្វើរបាយការណ៍

**មាត្រា៤៥.-**

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៦.-**

រៀងរាល់ដំណាច់ខែ ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវផ្ញើប័ណ្ណបង់ប្រាក់ និងសលាកប័ត្រចំណូលថវិកាថ្នាក់ជាតិ (ច្បាប់ថតចម្លងចំនួនមួយច្បាប់) ទៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានការអនុវត្តចំណូល។

រៀងរាល់ដំណាច់ខែ មន្ទីរជំនាញ និងអង្គភាព នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវផ្ញើប័ណ្ណបង់ប្រាក់ និងសលាកប័ត្រចំណូលថវិកាថ្នាក់ក្រោមជាតិ (ច្បាប់ថតចម្លងចំនួនមួយច្បាប់) ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតាមដានការអនុវត្តចំណូល។

**មាត្រា៤៧.-**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្ដីពីស្ថានភាពនៃការអនុវត្តចំណូលនិងបំណុលមិនមែនសារពើពន្ធ ផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុន÷

- ថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**មាត្រា៤៨.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃការអនុវត្តចំណូលនិងបំណុលមិនមែនសារពើពន្ធ និងមន្ទីរជំនាញ នៃរាជធានី ខេត្ត ក្រោមឱវាទសាមីក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ផ្ញើទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីធ្វើរបាយការណ៍បូកសរុប និងផ្ញើទៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុន÷

- ថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**មាត្រា៤៩.-**

ក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើរបាយការណ៍ស្តីពីស្ថានភាពបញ្ចូល បញ្ចេញទិដ្ឋាការស្អិតប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយមានរាយលម្អិតតាមប្រភេទ និងតម្លៃទិដ្ឋាការស្អិត និងតាមអង្គភាពប្រើប្រាស់ដែលស្ថិតក្រោមឱវាទ ដូចជា ការប្រើប្រាស់ទិដ្ឋាការស្អិតនៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារព្រំដែនផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា តាមបណ្តាស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅបរទេស ដោយផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុន÷

- ថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើរបាយការណ៍ស្តីពីការផ្តល់ទិដ្ឋាការអេឡិចត្រូនិចប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយមានរាយលម្អិតតាមប្រភេទ និងតម្លៃទិដ្ឋាការនីមួយៗ ផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទន្ទឹមនឹងរបាយការណ៍ស្តីពីស្ថានភាពបញ្ចូល បញ្ចេញទិដ្ឋាការស្អិតប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

**មាត្រា៥០.-**

នៅរៀងរាល់ដំណាច់ឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការបូកសរុប និងផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តចំណូលប្រចាំឆ្នាំរបស់ខ្លួនឱ្យបានត្រឹមត្រូវ ជាមួយនឹងគណនេយ្យករសាធារណៈនៅអគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើតារាងវិភាគតួលេខអនុវត្តចំណូលប្រចាំឆ្នាំ ដោយបង្ហាញអំពីតួលេខចំណូលក្នុងឆ្នាំសុទ្ធសាធ និងតួលេខចំណូលនៃឆ្នាំមុនដែលមកកត់ត្រាក្នុងឆ្នាំនេះ និងត្រូវធ្វើរបាយការណ៍វិភាគលទ្ធផលនៃការអនុវត្តចំណូលប្រចាំឆ្នាំ ដោយធ្វើសេចក្តីពន្យល់ ឬបញ្ជាក់អំពីមូលហេតុកើន ឬថយ លើលទ្ធផលនៃការអនុវត្តចំណូលប្រចាំឆ្នាំលម្អិតទៅតាមមុខចំណូលនីមួយៗ ប្រៀបធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ផ្ញើទៅអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

របាយការណ៍វិភាគលទ្ធផលនេះ ត្រូវធ្វើជាមូលដ្ឋាននៃកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

## ជំពូកទី៦
## ការជម្រះបញ្ជី នៃបំណុលមិនមែនសារពើពន្ធ

**មាត្រា៥១.-**

បំណុលមិនមែនសារពើពន្ធ អាចជាកម្មវត្ថុនៃការជម្រះបញ្ជី ក្នុងករណីដូចខាងក្រោម÷

- កូនបំណុលបាត់ខ្លួន ស្វែងរកពុំឃើញ
- កូនបំណុលត្រូវបានប្រកាសក្ស័យធន ដោយស្ថាប័នមានសមត្ថកិច្ច
- បំណុលដែលត្រូវបានកំណត់ជាកម្មវត្ថុ នៃការជម្រះបញ្ជី ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬដោយការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា៥២.-**

ការជម្រះបញ្ជី នៃបំណុលមិនមែនសារពើពន្ធ ពុំមានអានុភាពគតិយុត្តធ្វើឱ្យថ្លោះសិទ្ធិរបស់រដ្ឋ ក្នុងការតឹងទារបំណុលមិនមែនសារពើពន្ធឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិតឹងទារបំណុលមិនមែនសារពើពន្ធដើម្បីបង់ចូលថវិកាជាតិ ក្នុងករណីដែលមូលហេតុនៃការជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធ ដូចមានចែងក្នុងមាត្រា៥១ ខាងលើត្រូវបាត់បង់។

វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជី នៃបំណុលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## ការត្រួតពិនិត្យនិងវាយតម្លៃលើការប្រមូលចំណូលមិនមែនសារពើពន្ធ

**មាត្រា៥៣.-**

ការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី៨
## អធិការកិច្ច និងសវនកម្ម

**មាត្រា៥៤.-**

ក្នុងករណីសង្ស័យណាមួយ ដើម្បីត្រួតពិនិត្យតាមដានលើការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ការតឹងទារបំណុលមិនមែនសារពើពន្ធ ព្រមទាំងការជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការណាមួយ ដូចខាងក្រោម÷

- ស្នើសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យធ្វើសវនកម្មផ្ទៃក្នុង ឬអធិការកិច្ចដោយឡែក

- ធ្វើអធិការកិច្ចហិរញ្ញវត្ថុ លើសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ស្នើក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ធ្វើអធិការកិច្ចលើក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៥៥.-**

ការអនុវត្តការប្រមូលចំណូលនិងការតឹងទារបំណុលមិនមែនសារពើពន្ធ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវទទួលរងអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬអធិការកិច្ច និង/ឬសវនកម្មដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## ការលើកទឹកចិត្តនិងការដាក់ទណ្ឌកម្ម
### ផ្នែកទី១
### ការផ្តល់រង្វាន់លើកទឹកចិត្ត

**មាត្រា៥៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឬមន្ត្រីរាជការសាធារណៈ មានស្នាដៃក្នុងការអនុវត្តការងារប្រមូលចំណូល និងតឹងទារបំណុលមិនមែនសារពើពន្ធ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព អាចទទួលបានការលើកទឹកចិត្ត តាមរយៈការផ្តល់ប្រាក់រង្វាន់ ឬជាប័ណ្ណសរសើរ ឬជាគ្រឿងឥស្សរិយយស ឬឋានន្តរសក្តិ តាមការសម្រេចរបស់រាជរដ្ឋាភិបាល ឬតាមការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា៥៧.-**

ការពិនិត្យ វាយតម្លៃ និងផ្តល់ការលើកទឹកចិត្ត ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យជាសារវ័ន្ត ដូចខាងក្រោម÷

- ការរកឃើញ និងការប្រមូលចំណូលលើប្រភពចំណូលថ្មី
- លទ្ធផលនៃការអនុវត្តចំណូលប្រចាំឆ្នាំសម្រេចបានលើសលទ្ធផលនៃការអនុវត្តចំណូលឆ្នាំមុន
- ការប្រមូលចំណូលដែលស្ថិតនៅទីតាំងឆ្ងាយ ដាច់ស្រយាល និងស្ថានភាពលំបាកនៃគមនាគមន៍
- ការប្រមូលចំណូលធ្វើឡើងនៅថ្ងៃឈប់សម្រាក ឬថ្ងៃបុណ្យជាតិ
- ការប្រមូលចំណូលដែលមានហានិភ័យដល់សុខភាព និងសុវត្ថិភាពការងារ
- ការតឹងទារបំណុលរ៉ាំរ៉ៃ ទទួលបានលទ្ធផលតាមរយៈការខិតខំប្រឹងប្រែងចាត់វិធានការ និងសកម្មអនុវត្តការតឹងទារបំណុល។

**មាត្រា៥៨.-**

គោលការណ៍នៃការផ្តល់ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវសម្រេចដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធី នៃការត្រួតពិនិត្យ ការវាយតម្លៃ និងការផ្តល់ការលើកទឹកចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២

## ទណ្ឌកម្ម

**មាត្រា៥៩.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដែលមិនបានប្រគល់កិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងៗ ឬមិនបានប្រគល់ ឬយឺតយ៉ាវក្នុងការប្រគល់ ឬរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធ និងរបាយការណ៍ពាក់ព័ន្ធការអនុវត្តចំណូលមិនមែនសារពើពន្ធ ឬរក្សាទុកចំណូលលើសពីការកំណត់ ដូចមានចែងក្នុងជំពូកទី៣ ជំពូកទី៤ ជំពូកទី៥ និងជំពូកទី៦ នៃអនុក្រឹត្យនេះ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមិនត្រឹមត្រូវ ឬមិនគ្រប់ជ្រុងជ្រោយ អាចជាកម្មវត្ថុនៃការអនុវត្តវិធានការរឹតត្បិតផ្សេងៗ រួមទាំងការរឹតបន្តឹងចំណាយ នៅក្នុងការរៀបចំនិងការអនុវត្តថវិកាប្រចាំឆ្នាំ។

វិធាននិងនីតិវិធីលម្អិត នៃការរឹតបន្តឹង ឬលើកទឹកចិត្ត ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦០.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ មន្ត្រីរាជការសាធារណៈដែលត្រូវបានរកឃើញថាមិនគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត។

**មាត្រា៦១.-**

ហាមដាច់ខាតនូវការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយចំពោះ ឬមិនចំពោះ ក្រៅពីចំណូលដែលបានអនុញ្ញាតដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ទោះបីជាចំណូលទាំងនោះស្ថិតក្នុងប្រភេទណាក៏ដោយ។

រជ្ជទេយ្យករចំណូល ភ្នាក់ងារប្រមូលចំណូល ឬមន្ត្រីរាជការសាធារណៈដែលបានប្រព្រឹត្តអំពើមិនប្រក្រតី ឬអនុវត្តមិនបានហ្មត់ចត់ ពាក់ព័ន្ធការប្រមូលចំណូល ការតឹងទារបំណុល ការគ្រប់គ្រងចំណូល ការបង់ចំណូល ឬអំពើពាក់ព័ន្ធការគ្រប់គ្រងប្រាក់កាសសាធារណៈ ឬល្មើសនឹងវិន័យថវិកាដែលមានជាអាទិ៍ លាក់លៀមប្រភពចំណូល, គេចវេះមិនព្រម បង់ចំណូល, ខ្វះការកត់ត្រាក្នុងរបាយការណ៍បង់ចំណូល, មិនបានធ្វើរបាយការណ៍បង់ចំណូល, ព្រងើយកន្តើយមិនចាត់វិធានការលើការតឹងទារបំណុល និងមិនចាត់វិធានការប្រមូលចំណូលទុកឱ្យមានការកកើតបំណុលថ្មីៗ ត្រូវទទួលខុសត្រូវដោយផ្ទាល់ទៅតាមកម្រិតនៃបទល្មើស ឬកំហុស ដែលបានប្រព្រឹត្ត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ព្យសនកម្ម ដែលកើតមានឡើង ដោយការបំពានកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ នឹងក្លាយជាបំណុលផ្ទាល់ចំពោះសាមីមន្ត្រីរាជការសាធារណៈនោះ ដែលត្រូវសងនិងបង់ចូលថវិការដ្ឋវិញ ដោយមិនគិតទណ្ឌកម្មរដ្ឋបាល និងទោសទណ្ឌដទៃទៀតដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៦២.-**

បុគ្គលឯកជន ដែលជាភាគីនៃកិច្ចសន្យាជាមួយរដ្ឋទាំងឡាយណា ដែលមិនគោរពតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធកាតព្វកិច្ចបង់ចំណូល ត្រូវទទួលការដាក់ពិន័យ ដោយអនុលោមតាមមាត្រា៤២ និងមាត្រា៤៣ នៃអនុក្រឹត្យនេះ និងតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៦៣.-**

កិច្ចសន្យា ឬកិច្ចព្រមព្រៀង ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលត្រូវបានបង្កើតឡើងក្រោយអនុក្រឹត្យនេះ ចូលជាធរមាន ដែលមិនបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកថាគ្មានសុពលភាព។

**មាត្រា៦៤.-**

កិច្ចសន្យា ឬកិច្ចព្រមព្រៀង ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលបានធ្វើមុនអនុក្រឹត្យនេះចូលជាធរមាន ដែលពុំទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើនីត្យានុកូលកម្មឡើងវិញ តាមវិធាននិងនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៥.-**

ចំពោះមន្ត្រីរាជការសាធារណៈ ដែលបានប្រព្រឹត្តអំពើល្មើសនឹងមាត្រា៦៣ និងមាត្រា៦៤ ខាងលើ ត្រូវទទួលរងទណ្ឌកម្មដោយអនុលោមតាមមាត្រា៦០ នៃអនុក្រឹត្យនេះ។

**មាត្រា៦៦.-**

ចំពោះបុគ្គលឯកជន ដែលបានប្រព្រឹត្តអំពើល្មើសនឹងមាត្រា៦៣ និងមាត្រា៦៤ ខាងលើ ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការខូចខាតរបស់ខ្លួនទាំងស្រុង ដោយបាត់បង់សិទ្ធិទាមទារសំណង និងត្រូវបង់ប្រាក់ផាកពិន័យ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីផ្សេងទៀត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**មាត្រា៦៧.-**

កិច្ចដំណើរការនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបន្តនិរន្តរភាពរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា៦៨.-**

ដើម្បីធានាការអនុវត្តអនុក្រឹត្យនេះប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងទម្រង់គំរូនានា ដែលកំណត់ពីយន្តការ វិធាន និងនីតិវិធីលម្អិតនៃការប្រមូល ការបង់ ការគៀរគរ ការកត់ត្រា ការតាមដាន និងការត្រួតពិនិត្យវាយតម្លៃលើចំណូលមិនមែនសារពើពន្ធ ព្រមទាំងការចាត់វិធានការតឹងទារបំណុលមិនមែនសារពើពន្ធ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

**មាត្រា៦៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានគ្រប់អង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៩ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ